គេមិនដឹងឡើយថា នាងបានដុតចោលសំណុំផ្កាចុងក្រោយនោះទៅហើយ។

បន្ទាប់ពីឆ្លងកាត់នូវ បណ្ដាថ្ងៃដ៏ល្អស្រស់ស្រោយអារម្មណ៍អណ្ដែតអណ្ដូង និងទទួលបានការស្រលាញ់ពីមនុស្សប្រុសសឹងឥតខ្ចោះម្នាក់ក្រោយមកក៏ទទួលបានការឈឺចាប់វេទនាវែងអន្លាយដល់ទៅជាងមួយពាន់ថ្ងៃ ទីបំផុត សន្យាបានសម្រេចចិត្តថាបោះបង់ចោល ការតស៊ូក្រាញននៀលព្រោះចង់ដណ្ដើមមកវិញនូវអ្វីដែលខ្លួនយល់ថា វាសមតែជារបស់ខ្លួន។ នាងទើបនឹងគិតយល់ អំពីអត្ថន័យពិតនៃសេចក្ដីស្រឡាញ់ដែលតាមពិតទៅមិនមែនរឿងចាញ់ឈ្នះត្រឹមត្រូវយុត្តិធម៌ឬអត់ រឿងសំខាន់គឺធ្វើដើម្បីធ្វើឱ្យមនុស្សម្នាក់នោះ បានសប្បាយចិត្តនិងបានសុខ។

ទំនាក់ទំនងមួយល្អយ៉ាងណាក្ដី វាអាចនឹងបញ្ចប់ទៅបានពីព្រោះមនុស្សពីរនាក់មិនសក្ដិសមនឹងគ្នា បើទោះជាពួកគេស្រលាញ់គ្នាខ្លាំងប៉ុណ្ណាក្ដី គេមិនគួរមានៈដល់មានវិបត្តិដោយសារតែចិត្តចចេសឡើយ។

ការឆាប់ទទួលយកការពិតប្រហែលជាជម្រើសល្អជាងសម្រាប់សន្យាគិតក្នុងពេលនេះ។

នាងដើរមួយៗបកមករកទីជម្រកស្របពេលទិនករយាងចាកចោលនភាល័យទាំងស្រុងផ្លាស់វេនឱ្យសន្ធិយាមកគ្រប់គ្រងលើជីវិតមនុស្សសត្វ។

ពិដោរផ្កាព្រៃនៅតែចោលគន្ធាដូចរាត្រីដំបូងដែលនាងមានវាសនាបានជួបបុរសនោះនាទីជម្រាលជើងភ្នំ។ សូម្បីតែបាច់ផ្កាចុងក្រោយក៏យើងបានដុតចោលក្លាយជាផេះផង់ហើយដែរហេតុអ្វីចិត្តយើងមិនព្រមរលប់ស្រមោលគេ?

នាងសួរខ្លួនឯងទាំងឈោងដៃបិទទ្វារផ្ទះឈើដោយមិនយកចិត្តទុកដាក់ចំពោះចង្កៀងម៉ាងសុងខាងក្នុងជះពន្លឺស្រស់រ៉ូមែនទិកប្លែកសោះ។ យប់នេះ នាងគិតថា ម្ដាយធម៌នឹងស្នាក់នៅជាមួយ កំដរអារម្មណ៍ទទេស្អាតរបស់នាង ហើយតទៅនាងនឹងធ្វើចិត្តបាន។

ដោយឈរផ្អែកស្នងនឹងទ្វារបិទ នាងទន្ទេញម្នាក់ឯងទាំងបិទភ្នែកហត់នឿយ « រៀនពី បទពិសោធន៍នេះសន្យា! រក្សាទុកនូវការចងចាំពីអនុស្សាវរីយ៍ល្អ ៗ !សេចក្ដីស្នេហា មិនមែនមានន័យថាយើងត្រូវតែ រស់នៅក្បែរទ្រូងគេ ទើបហៅថាស្រលាញ់គ្នាពិតនោះទេ! អនុញ្ញាតឱ្យគេរស់នៅបានល្អបានសប្បាយឯងអាចធ្វើបាន! ដើម្បីគេ ដើម្បីស្នេហាមួយនេះ!»

នារីងើបមុខសម្លឹងបរិយាកាសកម្សត់ដែលជារៀងរហូតទៅ នាងគិតថាលែងទន្ទឹងរង់ចាំវត្តមានគេត្រឡប់មកវិញទៀតហើយ។

របស់មួយរំញោចភ្នែកហត់នឿយរបស់នាងឱ្យបើកចិញ្ចាចស្រឡះស្រឡាំមកវិញ។

នុះ!បាច់ផ្កាធំជាងមុនស្រស់ប៉ប្រិមនៅលំអក្នុងថូលើតុវល្លិផ្តៅ។

តើវាជាក្តីស្រមៃមែនដែរទេ? នាងដើរមួយៗមក ទាំងដកដង្ហើមវែងៗ លូកដៃចាប់ស្ទាប ស្រទាប់ផ្កា។

ផ្កាចាស់ចាកចេញបាត់របស់ថ្មីចូលមកជំនួសវិញនេះជាវាលវដ្តសង្សារពិតក្នុងលោកយើងនេះពិតមែន។

ស្រទាប់បុស្បាក្រាស់ ដិតដាមដោយពណ៌សម្រស់ ញ៉ាំងឱ្យចិត្តដែលតែងក្តួចមេត្រី ហាក់ស្រាលស្បើយពីទុក្ខលួល្ហេវ។

«ចូររៀនស្រលាញ់មនុស្សដែលល្អនឹងយើង ហើយឈប់ចំណាយពេលរង់ចាំ នូវអ្វីដែលយើងដឹងហើយថាមិនសមនឹងយើង!»

នាងនិយាយតិចៗប្រាប់ខ្លួនឯង មុនហាររហៅឮៗ៖

«ម៉ែនៅឯណាម៉ែ?!»

នាងគិតថា ម្តាយធម៌បានបេះបុប្ផាមកលំអកំដរនាង ។

ស្ងាត់សូន្យគ្មានសំឡេងតបទេ។

នាងអោនស្រូបយកគន្ធាពីទងបុប្ផាទាំងញញឹម ដឹងអី សំបុត្រមួយជ្រុះចេញមក។

ស្រីស្អាតភាំងបន្តុ។

នាងលូកដៃដែលមានម្រាមទន់ខ្សោយញ័រទទ្រើកគ្មានកម្លាំងទៅលាមកអាន។

តួអក្សរចាស់ បានផ្លាស់សំណេរថ្មី «បើសិនស្នេហាយើងជាផ្កាកុលាប បងនឹងបង្កាត់ពូជថ្មី ដែលគ្មានទេបន្លា!»

ស្រីស្អាតងាកក្រោយឃ្វាំងសម្លឹងជុំវិញផ្ទះ។ ពីក្រោយវាំងនន បាំងបិទទីដំណេក  នាងឃើញជើងមួយគូនិងកង់រទេះ។ ដៃនាងញ័ររលេះ ជើងទន់ខ្សោយឈានទៅរករៀមក៏មិនបាន។ មាត់នាងចង់ញញឹមតែទឹកភ្នែកនាងស្រក់តក់ៗ ទាំងមិនមានសំណោកអ្វីឡើយ។ គេអាចសរសេរខ្មែរវិញបាន តើគេដឹងខ្លួន មកវិញហើយ?

ដោយការព្យាយាមស្វែងរកអតីតកាលមកវិញ គេបានលះបង់រាងកាយរបស់ខ្លួន។ ស្រីតូចគ្រវីក្បាលតតាត់ព្រោះមិនជឿភ្នែក តែទីបំផុត នាងក៏រត់សំដៅទៅ ។

សន្យាលុតជង្គង់ពីមុខរទេះអ្នកជំងឺ ស្របពេលគេរែកវាំងននបង្ហាញខ្លួន។

បុរសម្នាក់នេះបញ្ចេញទឹកមុខដូចបេះបិទកាលពីថ្ងៃដំបូងដែលគេនាំនាងទៅអង្គុយគយគន់ដងអូរ ហើយសារភាពពីអតីតកាល បុគ្គលភាពរបស់គេប្រាប់នាងគ្មានសេសសល់។

ច្បាស់ណាស់ ទោះបីមុខគេរងរបួសមួយចំហៀង នាងនៅតែអាចទទួលដឹងពីអារម្មណ៍គេបានដោយបេះដូង។

នាងលូកដៃទៅស្ទាបផ្ទៃមុខគេទាំងមិននិយាយអ្វីចេញបណ្តោយឱ្យភក្ត្រាទាំងសងត្របាញ់សម្លឹងរកគ្នាជំនួសឱ្យវាចានឹករលឹក។

«អូនស្គមម៉េះ ?»

នេះជាសម្តីបីម៉ាត់បន្ទាប់ពី៦ឆ្នាំដែលគេភ្លេចខ្លួនឯង។

ប្រអប់ដៃគេ លូកមកពីលើដៃនាងដែលកំពុងអង្អែលថ្ពាល់រងរបួស។

«៦ឆ្នាំហើយ បងនឹកអូនណាស់សម្លាញ់ចិត្ត!»

ដៃគេរមៀលចុះមកបង្អួសបន្ទើរមកលើកំភួនដៃតូចរាវរបស់ស្រីស្នេហ៍ មុនពេលបង្វិលចាប់ទាញម្រាមទាំងប្រាំមកផ្អឹបក្បែរបបូរមាត់។

នាងសម្លឹងគេទាំងទឹកភ្នែក។

បុរសនេះ មិនត្រឹមតែចងចាំ មកវិញគ្រប់យ៉ាងប៉ុណ្ណោះទេ ប៉ុន្តែកាយវិការគេហាក់បីដូចជាកំពុងចង់លេប ថើបត្របាក់គ្រប់ផ្ទៃស្បែកទន់រលោងលើរាងកាយរបស់នាង។

Lorenzoគ្រាន់តែសង្កត់បបូរមាត់សើមៗ ទន់ៗ ក្តៅៗនៅក្បែរម្រាមដៃនាងសោះ ភាពញាប់ញ័រក៏បានចាប់ផ្តើមមានអនុភាពមកលើរាងកាយស្រីតូចទាំងស្រុង។

«Loren!»

នាងហៅបុរសនេះតិចៗ នៅពេលដែលគេងប់ងុលឈ្ងោកថើបសំដៅមកដើមស្មានិងគល់តែម្តង។

«កុំឃាត់បងមិនឱ្យស្រលាញ់អូន!»

សំដីខ្សឹបរបស់នាយស្រទន់ហើយជិតនឹងត្រចៀកនាងមុនពេលគេបង្កើតស្នាមថើបក្ដៅគគុកនៅបរិវេណនោះ។

«បងឯងនឹកឃើញវិញហើយ?!»

នរៈងើបមុខមកវិញដោយលូកប្រអប់ដៃទាំងទ្វេទៅត្រកងទ្រូងនាងទាំងសងខាង ព្រមទាំងប្រើកម្លាំងលើកស្ទួយរាងកាយស្រីតូចម្នាក់នេះឱ្យក្រោកមកឈរចំពីមុខខ្លួន។

គេដឹងខ្លួនមកវិញហើយ? នេះជាសំណួរដែលនាងសួរខ្លួនឯងយ៉ាងរហ័ស។

បុរសនេះអង្គុយលើរទេះរុញ គេសមណាស់តែពិការ ចុះហេតុអ្វីបានជាកម្លាំងគេដូចជាមិនបានកើតអីទាំងអស់?

«នាងជាអ្នកណា?»

«កុំនិយាយរឿងផ្សេង! កុំសួររឿងផ្សេង ក៏កុំនិយាយរឿងដែលមិនទាក់ទង! សួរមក ថាខ្ញុំជាសង្សាររបស់ខ្លួនពិតមែនដែរអត់!»

ទាំងនេះជាពាក្យសន្ទនាដ៏ឈឺចាប់ដែល នាងបានទទួលពីគេបន្ទាប់ពីឃ្លាតគ្នាអស់៦ឆ្នាំ ឥឡូវនេះគេប្ដូរវាមកជា«កុំឃាត់បងមិនឱ្យស្រលាញ់អូន!» តើ ដើម្បីទទួលបានការចងចាំទាំងនេះមកវិញគេបានលះបង់ចោលរាងកាយដ៏ស្រស់សង្ហានេះ ពិតមែន? គេពិការជារៀងរហូតហើយមែនទេ?

«ជើងបងឯងកើតអី?» សន្យាហារទម្រាំចេញជាមួយសព្ទសំឡេងស្អកស្អា។

បុរសនេះរកឃើញភាពខុសគ្នាក្នុងប្រតិកម្មរបស់សន្យាធៀបជាមួយពិនណា។

សម្ដីនាង សំឡេងនាង កាយវិការនាង បញ្ជាក់ប្រាប់បេះដូងនាយថាទោះគេក្លាយជាអ្វីក៏នាងនៅតែនៅក្បែរគេមិនបោះបង់ដែរ។

គេនៅទ្រឹង ប្រើបបូរមាត់ស្ទើរស្ទើស្ទើរញញឹម សម្លឹងខ្សែទឹកភ្នែកនៃបរិសុទ្ធចិត្តដែលតូចនារីកំពុងបង្ហូរមកខ្លោកៗ។

«ម៉េចក៏បងឯងជិះរទេះ? បងឯងកើតអីគេ អ្ហះ?!»

គេក្រោកឈរមកជាមួយនឹងបេះដូងរំជួលរំជើប។ រាងកាយខ្ពស់ស្រាវបិទបាំងបិទស្បៃរាត្រីកាលនៅពីក្រៅខ្នម ឱ្យមើលលែងអាចមើលឃើញ រូបរាងរាវតូចនៃស្រីក្មេងដែលកំពុងសុខសាន្តក្នុងរង្វង់ដៃ

ផ្ទឹបជាប់លង្វែកទ្រូងក៏ជាភាសាសម្ងាត់ដែលចង់ប្រាប់ឱ្យនាងដឹងដែរថា បុរសម្នាក់នេះនឹងតែងតែនៅទីនេះដើម្បីនាងជារៀងរហូតទៅ។

នាងស្រលាំងកាំងដែលគេក្រោកមកបាន ក៏ភាន់ភាំងមិនឈប់នឹងការក្រសោប ឱបប្រាណរបស់នាយណែនក្តន់រកតែរើចេញពិនិត្យអ្វីក៏មិនបាន។

«បងឯងអត់កើតអីផងអង្គុយលើរទេះធ្វើអី?!»

នាងសួរង៉ុលៗហើយប្រឹងរើដើម្បីបានទទួលសេរីភាពចេញពីទ្រូងនាយនឹងអាលបានពិនិត្យពិច័យ Lorenzo ឱ្យបានពេញភ្នែក។ ដៃស្រស់ស្រីរុញទ្រូងនាយផងស្ដីបន្ទោសក្នក់ក្នាញ់ផង៖

«មនុស្សខូច!!! ពូកែធ្វើពុតណាស់!»

Lorenzoញញឹមតិចៗ រួចទើបបន្ធូរម្រាមដៃបន្តិចម្តងចេញពីខ្នងនាង។ ខាងប្រុសកំពុងតែមានអារម្មណ៍រំជើបរំជួលខ្លាំង បន្ទាប់ពីបានគ្រប់គ្រងនាងពេញក្នុងទូទាំងរាងកាយ វាដូចជាសកម្មភាពដើម្បីតែពិពណ៌នាថា តទៅគេនឹងមិនចាកចេញឆ្ងាយពីនាងទៀតឡើយ។

«បងមកវិញហើយ! អត់មានគេសប្បាយចិត្តទេ?ថាយំ យំមែន!»

គេបង្ហួសដៃមកកាន់ត្រគាកនាង ហើយបបូរមាត់ឱនផ្ដិតទឹកភ្នែកនាង – ជាមួយស្នូរដង្ហើមស្នេហាជាមួយតម្រូវការជីវិតទៅមុខមានតែនាងហើយនឹងគេ។

«តែបងនឹងរៀបការ!»

នាងនិយាយដោយតូចចិត្ត បណ្ដាលឱ្យគេរឹតតែរុញចង្កេះមកកៀកប្រាណស្រីល្អ ព្រោះចិត្តអាណិតជ្រាលជ្រៅ។

Lorenzoនិយាយតិចៗឌឺដង៖

«ហ្នឹងហើយ! ហើយឥឡូវ កំពុងត្រៀមផ្សំដំណេកសាកមើលឱ្យថ្មីកមុនរាត្រីទឹកឃ្មុំ!»

នាងច្រានវាយតប់គេព្រោះគ្នាន់ក្នាញ់៖

«កុំមកសង្ស៊ឹមLorenzo!»

កម្លាំងបដិសេធទន់ជ្រាយតូចខ្សោយរបស់នាងកាន់តែស៊ិចស៊ីឡើងថែមទៀតលើកំសួលភ្លើងស្នេហ៍ដែលបំពក់ក្នុងទ្រូងប្រុសស្អាត។ គេដឹងថានាងកំពុងត្រូវការស្នេហានេះ ហើយត្រូវការគេ ដូច ដែលគេកំពុងតែត្រូវការនាង។

គេថើបស្រីម្តងទៀតរហូតដល់បបូរមាត់ទាំងសង ក្លាយមកជាកម្មសិទ្ធិឱ្យគ្នាទៅវិញទៅមក រហូតដល់នាងព្រមឈប់ច្រាន ឈប់បដិសេធ  បែរជាមកឱបនាយវិញ លះបង់ចោលភាពរារែក  ក្តីព្រួយបារម្ភផងទាំងឡាយ ។

 ពេលវេលារំលងទៅយឺតៗ ស្ងប់ស្ងៀមអបអរ ហាក់បីដូចជារាត្រីកាលមានចេតនាជួយលាក់ បង្កប់គូមួយនេះ ឱ្យលង់ជ្រៅក្នុងសុភមង្គលដែលមនុស្សម្នារស់រានលើផែនដីរមែងប្រាថ្នាចង់បាន។ រហូតដល់វារចាកចេញពីអារម្មណ៍រំជើបរំជួលបានស្រួលបួលបន្តិចខាងប្រុសជាអ្នកវាចាប្រាប់មុនៈ

«សន្យា! ស្តាប់ណាកូននាគរបស់បង! តទៅ គ្មានអ្នកណានៅចំចន្លោះកណ្តាលរវាងពួកយើងតទៅទៀតទេ! ពាក្យសម្តីរាប់សែនក៏នៅតែ មិនអាចពន្យល់អស់ទំហំចិត្តបងនៅឡើយ ថាសម្រាប់ប្រុសម្នាក់នេះ សន្យាជាមនុស្សស្រីអស្ចារ្យយ៉ាងណា !!! តែបងអាចប្រាប់បានត្រឹមថា  វាអស្ចារ្យណាស់ដែលភ្ញាក់ពីគេងរាល់ថ្ងៃឃើញអូន! អូនធ្វើឱ្យបេះដូងរបស់បងកក់ក្តៅមិនថាបងជាអ្នកណាមានលុយឬគ្មាន  ពិការឬក្រោកឈរ មិនថាគ្រប់យ៉ាងប្រែទៅជាយ៉ាងណា មិនថាស្នេហានេះនៅឆ្ងាយរហូតដល់ជើងមេឃ ក៏បងនៅតែទទួលអារម្មណ៍ដឹងបានដោយមិនចាំបាច់បង្ខំ! !!!!បងស្រលាញ់អូន!»

អ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការយកចិត្តទុកដាក់តាមដានវគ្គបញ្ចប់នៃជីវិតស្នេហ៍ សន្យា និងLorenzo។

សូមសេចក្តីស្នេហាពិតកើតមានក្នុងជីវិតរបស់អ្នកអានគ្រប់គ្នាកុំបីខាន!

**ចប់**

ទំនាក់ទំនងជាវសៀវភៅនេះ ០១៥ ២១ ៣១ ១១